# វប្បធម៌ខ្មែរ និង ជនជាតិសៀម



ប្រាសាទអង្គរវត្ត

សៀមបានទទួលយកវប្បធម៌ខ្មែរហើយរួមគ្នាគោរពនិងប្រតិបត្តិតាម កសាងជាគ្រួសារ កសាងជាសង្គមជាតិថ្មីមួយលើអតីតទឹកដីខ្មែរនិងមន បង្កឱ្យប្រទេសសៀមទទួលនូវការរីកចម្រើនជាងខ្មែរ ដែលជាម្ចាស់វប្បធម៌និងម្ចាស់ទឹកដី ។ តើខ្មែរជាអ្នកណា? អ្វីខ្លះជាវប្បធម៌ខ្មែរ? តើសៀមជាអ្នកណា? មកពីណា?

ខ្មែរជាមនុស្សស្រឡាញ់សេចក្តីសុខក្សេមក្សាន្តមិនចូលចិត្តឈ្លោះគ្នាឡើយ ជាជនជាតិមួយកើតនិងរស់នៅលើទឹកដីជ្រោយសុវណ្ណភូមិតាំងពីយូរលង់ណាស់មកហើយ ដែលយោងតាមវត្ថុតាងនៅស្ថានីយបុរេប្រវត្តិ ល្អាងស្ពាននាភាគពាយ័ព្យ ប្រទេសកម្ពុជាបង្ហាញឱ្យដឹងថា មនុស្សខ្មែរបានកើត និងរស់នៅតំបន់នេះតាំងពី ៥០០០ឆ្នាំមុនគ្រឹស្តសក-រាជ។ មនុស្សខ្មែរប្រតិបត្តិតាមវប្បធម៌ខ្មែរ ដែលជាវប្បធម៌បណ្តុះពូជខ្មែរឱ្យមានអត្តចរិតល្អដឹងខុសត្រូវ គោរពច្បាប់និងប្រពៃណីទំនៀមទម្លាប់ គោរពប្រណិប័តន៍មេបា ពិសេសគោរពម៉ែឪ គ្រូអាចារ្យ ចាស់ទុំយ៉ាងខ្ជាប់ខ្ជួន ។ វប្បធម៌ខ្មែរ គឺភាសាខ្មែរ អក្សរសាស្ត្រខ្មែរ ជំនឿអ្នកតា ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា ប្រពៃណីទំនៀមទម្លាប់ខ្មែរ សិល្បៈ ។ល។ វប្បធម៌ខ្មែរផលិតចំណេះឱ្យខ្មែរមានប្រាជ្ញាវៃឆ្លាតនិងចូលចិត្តការបង្កបង្កើនមិនឈប់ឈរ ។ វប្បធម៌ខ្មែរបណ្តុះខ្មែរឱ្យក្លាយជាមនុស្សថ្លៃថ្នូរមានពូជពង្សវង្សត្រកូលជាអ្នកស្រុកមុនគេនៅតំបន់អាស៊ីអគ្នេយ៍ តាមរយៈការបង្កើតរដ្ឋនគរភ្នំ (ចិនហៅថា ហ្វូណន)នាដើមសតវត្សទី ១ នៃគ្រឹស្តសករាជ ដែលជាគ្រឹះអារ្យធម៌ខ្មែរ នាំទៅដល់ការបង្កើតអារ្យធម៌ខ្ពង់ខ្ពស់ថ្កុំថ្កើងរុងរឿងបំផុត នាសម័យអង្គរ (ឆ្នាំ៨០២-១៤៣១) ។

មនុស្សខ្មែរនិយាយភាសាខ្មែរ ជាអម្បូរភាសាមន-ខ្មែរ មានវ័យចំណាស់ក្នុងតំបន់ ។ សម័យហ្វូណន ភាសាខ្មែរបានទទួលនូវការរីកចម្រើនថ្មី ដោយមានការបូកបញ្ចូលគ្នារវាងភាសាខ្មែរបុរាណ និង ភាសាសំស្ក្រឹត ។

មនុស្សខ្មែរបានបង្កើតអក្សរខ្មែរនៅដើមសតវត្សទី ៧ មានភស្តុតាងជាសិលាចារឹកអក្សរខ្មែរដំបូងបំផុត នាគ្រឹស្តសករាជ ៦១១ (លេខក៦០០) នៅអង្គរបុរី ខេត្តតាកែវ [ព្រះរាជាណាចក្រកម្ពុជា] ហើយគឺអក្សរខ្មែរនេះហើយជាប្រភពដ៏មានតម្លៃបំផុត មានអត្ថន័យជាប្រវត្តិសាស្ត្រជួយអភិវឌ្ឍន៍សមត្ថភាពអ្នកស្រុកខ្មែរកាន់តែប្រសើរឡើង អាចបង្កបង្កើតទ្រព្យសម្បត្តិវប្បធម៌ជាច្រើនទុកឱ្យកូនខ្មែរជំនាន់ថ្មីធ្វើជាទុនអភិវឌ្ឍន៍មាតុភូមិរហូតសព្វថ្ងៃ ។ ទ្រព្យសម្បត្តិទាំងនោះមានអក្សរសាស្ត្រខ្មែរ សិល្បៈប្រពៃណីទំនៀមទម្លាប់ដ៏ល្អ ។ល។ និងប្រាសាទជាច្រើនពាសពេញព្រះរាជាណាចក្រកម្ពុជា ពិសេសប្រាសាទអង្គរវត្តដ៏ល្អវិចិត្រ នាសតវត្សទី ១២ និងប្រាសាទព្រះវិហារដ៏ល្អឯក នាសតវត្សទី ៩-១១ ។

**ឯសៀមមកពីណា? មកពីណា?**

ចម្លើយត្រឹមត្រូវហើយងាយចាំបំផុត គឺសៀមជាមនុស្សខ្ចាត់ព្រាត់មករស់នៅលើអតីតទឹកដីរបស់ខ្មែរ ។ ព្រោះយោងតាមលោក ហង់រី ម៉ាកម៉ង់ដេ ជនជាតិបារាំង បានសរសេរសៀវភៅមានចំណងជើងថា "អង្គរ " បោះពុម្ពផ្សាយដោយបណ្ណាគារអេគ្លីពនៅភ្នំពេញ ឆ្នាំ១៩៦០ បង្ហាញឱ្យដឹងក្នុងទំព័រទី ៩ថា "ពួកសៀមមានឈាមជ័រជាថៃ បានចុះពីប្រទេសចិនខាងត្បូងមករស់លើទឹកដីខ្មែរ ទទួលយកអារ្យធម៌ខ្មែរ ចាត់ទុកខ្មែរជាម្ចាស់លើពួកគេ តែពួកសៀមមិនបង្អង់យូរបានបះបោរប្រឆាំងនឹងម្ចាស់ខ្លួនឯង បង្កសង្គ្រាមបន្តបន្ទាប់ និងទីបំផុត ដណ្តើមយកទឹកដីកម្ពុជា។

ចំណែកលោក ដូហ្វាំង ម៉ីនីញេ ជនជាតិបារាំងដែរ បានសរសេរសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជា" បោះពុម្ពនៅក្រុងប៉ារីស ឆ្នាំ១៩៦៨ លោកបានសរសេរក្នុងទំព័រទី ៥០បញ្ជាក់ថា "ពួកសៀមបានបង្កើតរដ្ឋណានចាវ នាសតវត្សរ៍ទី ៨ នៅយូណានប្រទេសចិន ក្រោយមកបានជ្រៀតចូលមករស់នៅតាមជ្រលងភ្នំនៃភាគកណ្តាលតណ្ហចិន និងភូមា។ ឆ្លៀតឱកាសដែលភូមាត្រូវផ្តួលរំលំដោយពួកម៉ុងហ្គោល ដឹកនាំដោយ *យូប៉្លែខន* សៀមបានកាន់កាប់ផ្នែកជាច្រើននៃទឹកដីភូមា ហើយរៀនសូត្រតាមពួកម៉ុងហ្គោលខាងក្បួនទ័ព និងចម្លងយកអក្សរជ្រៀងខ្មែរទៅប្រើប្រាស់ ធ្វើឱ្យពួកសៀមកាន់កាប់បានរដ្ឋបាលខ្មែរនៅតំបន់ទន្លេមេណាម ។ អ្នកស្រុកខ្មែរបានតស៊ូប្រយុទ្ធប្រឆាំងការវាយលុកបំផ្លិចបំផ្លាញពីសំណាក់ពួកសៀម តែខ្មែរទទួលការខាតបង់ធំធេង ព្រោះពួកសៀមទទួលជោគជ័យ បង្កើតជារដ្ឋនិងរាជធានី សុខោទ័យ លើអតីតក្រុងរបស់ខ្មែរ។ " សូម្បីតែលោក អនុម៉ាន រាចាថន ជាសាស្ត្រាចារ្យបណ្ឌិតសៀមម្នាក់នៃសកលវិទ្យាល័យជូឡាឡុងកន និងជាប្រធានគណៈកម្មាធិការពិនិត្យឡើងវិញប្រវត្តិសាស្ត្រសៀម នាឆ្នាំ១៩៦៨ ក៏លោកបានសរសេរពីប្រវត្តិសាស្ត្រសៀម មានអត្ថន័យដូចលោក ម៉ាកម៉ង់ដេ និងលោក ម៉ីនីញេដែរ ។ លោក អនុម៉ានបានសរសេរសៀវភៅ "Essay on Thai Folklore" បោះពុម្ពផ្សាយនៅក្រុងបាងកកឆ្នាំ១៩៦៨ បញ្ជាក់ឱ្យដឹងលើទំព័រទី ៨-១១ថា សៀមមានប្រភពរស់នៅខាងត្បូងទន្លេយ៉ាងសេក្យាង Yang-tse Kiang ប្រទេសចិន ហើយចិនបានកត់ត្រាទុកក្នុងឯកសារ ហៅពួកសៀមថា "អ្នកព្រៃ"។ នាសតវត្សរ៍ទី ៧ ឬទី ៨ ពួកសៀមបានបង្កើតរដ្ឋឈ្មោះ "ណានចាវ" ដែលជាឈ្មោះបូកផ្សំគ្នារវាងភាសាសៀម និង ចិន។ ពាក្យណាន តាមភាសាចិនមានន័យថា ទិសខាងត្បូង ឯពាក្យ ចាវ តាមភាសាសៀមមានន័យថា ស្តេច។ នាដើមសតវត្សរ៍ទី ១៣ ក្រោមការដឹកនាំរបស់មេដឹកនាំពីរនាក់ ពួកសៀមដណ្តើមបានទឹកដីខ្មែរបង្កើតរដ្ឋសុខោទ័យ យកក្រុងឈៀងម៉ៃធ្វើជារាជធានី។

ចុងសតវត្សរ៍ទី ១៣ នាឆ្នាំ១២៨៣ ស្តេចទី ៣ នៃសុខោទ័យ ឈ្មោះ រាមកំហែង បានកាឡៃអក្សរខ្មែរបង្កើតជាអក្សរសៀម ដែលសៀមចាត់ទុកថា ជាឆ្នាំប្រវត្តិសាស្ត្រនៃវប្បធម៌សៀម ។

មុនមានអក្សររបស់ខ្លួន ពួកសៀមប្រើអក្សរខ្មែរ ហើយដោយសារតែគេប្រើប្រាស់អក្សរខ្មែរនោះហើយ ទើបសៀមអាចដណ្តើមនិងគ្រប់គ្រងបានសុខោទ័យ ។ កើតបានជារដ្ឋហើយ ក៏សៀមនៅតែប្រើប្រាស់អក្សរខ្មែរក្នុងផ្នែកព្រះពុទ្ធសាសនា ពិសេសសរសេរលើសាស្ត្រាស្លឹករឹត ព្រោះសៀមមានជំនឿថា អក្សរខ្មែរជាអក្សរសក្ការៈ ។ ទោះបីដណ្តើមដីពីខ្មែរបង្កើតបានរដ្ឋ យកអក្សរខ្មែរកាឡៃ បង្កើតបានអក្សរប្រើប្រាស់ហើយក៏ដោយ ក៏សៀមនៅតែលោភលន់បន្តប្រើកងទ័ពវាយដណ្តើមដីខ្មែរបន្ថែមទៀត ជាក់ស្តែងនាឆ្នាំ ១៤៣១ គឺ ១៩៣ឆ្នាំបន្ទាប់ពីដណ្តើមបាន សុខោទ័យ សៀមវាយដណ្តើមបាននិងកាន់កាប់ក្រុង អង្គរ លួចប្លន់យកសម្បត្តិវប្បធម៌ខ្មែរស្ទើរតែអស់ នាំឱ្យកើតជាព្រឹត្តិ-ការណ៍និរាសអង្គរ មនុស្សខ្មែរនិរាសព្រាត់ប្រាស់ បែកបាក់គ្រួសារទទួលការឈឺចាប់ជាពន់ពេករាប់រយឆ្នាំ ។

តាំងពីពេលនោះមក កូនខ្មែរជំនាន់ក្រោយពុំសូវស្គាល់និងយល់ដឹងពីវប្បធម៌ខ្មែរបានសព្វគ្រប់ឡើយ ជាហេតុនាំឱ្យមានឧបសគ្គចំពោះដំណើរអភិវឌ្ឍន៍សង្គមខ្មែរ ។ លោក អនុម៉ាន សរសេរនៅទំព័រ ៨៥ ក្នុង Essay on Thai Folklore ថា "សៀមបានទទួលយកបន្តិចម្តងៗ ភាសាមន និង ភាសាខ្មែរមួយចំនួនធំបញ្ចូលក្នុងភាសាសៀមនិងអក្សរសិល្ប៍សៀម" ។ តាមពិត សៀមនិយាយភាសាថៃជាអម្បូរភាសាមួយនៅយូណាន ប្រទេសចិន តែសៀមបានខ្ចីពាក្យខ្មែរជាច្រើនយកទៅប្រើថែមទៀត ដូចជាពាក្យខ្មែរថា តិះដៀល សៀមថា ទិតៀន កលសៀមថា កុន (ភាពយន្ត) កំពែង សៀមថា កាំផែង ថ្នល់សៀមថា ថាណុន រូបរាងសៀមថា រូបរ៉ាង សាលារៀន សៀមថា រោងរៀន ចម្រើនសៀមថា ចារើន ព្រះវិហារសៀមថា ប្រះវិហាន ដើមក្ទម្ពទេស សៀមថា ក្រៈទុំថេត ។ល។ ពិសេសលោក អនុម៉ាន សរសេរលើទំព័រទី ៨៧ថា រាជស័ព្ទដែលកំពុងប្រើសព្វថ្ងៃក្នុងរាជវង្សានុវង្សសៀម គឺជារាជស័ព្ទខ្មែរ ។

សៀមចម្លងយកប្រពៃណីទំនៀមទម្លាប់ល្អរបស់ខ្មែរ ដែលចេះគោរពម៉ែឪ គ្រូអាចារ្យ ចាស់ទុំស្រឡាញ់រាប់អានគ្នាជាបងប្អូន ប្រុសដណ្តឹងស្រី ស្លៀកពាក់ផាមួងចងក្បិន អាវកត្រង់ ស្លៀកសំពត់ សារុងចោមពុង ធ្វើផ្ទះរោងដោលរោងឌឿង។ ផ្នែកអក្សរសិល្ប៍ សៀមចម្លងយករឿងរាមកេរ្តិ៍ខ្មែរទៅធ្វើជារ៉ាម៉ាកេន ។ ម្ហូបស្ងោរជ្រក់បង្គា (សៀមប្តូរហៅ តុមយាំ) ហហ្មុក សម្លកកូរ ទឹកគ្រឿង...ក៏ជារបស់ខ្មែរ តែខុសគ្នាលើចំណុចហិរខ្លាំង ព្រោះសៀមចូលចិត្តប្រើម្ទេសច្រើន ។ ខ្មែរជាម្ចាស់ស្រុកមានទឹកដីនេសាទ ធ្វើស្រែចម្ការ មានទីលំនៅច្បាស់លាស់ មិនមែនជាអ្នកផ្លាស់ទី មានម្ហូបអាហារស្រស់ឆ្ងាញ់គ្រប់គ្រាន់ ទើបខ្មែរមិនប្រើម្ទេសច្រើនសម្រាប់ភូតអណ្តាតលើករសជាតិម្ហូបឡើយ ។ ផ្នែកសិល្បៈបុរាណ សៀមបានចម្លងពីខ្មែរ ដូចជា របាំក្បាច់បុរាណ ស្បែកធំ ភ្លេងពិណពាទ្យ តែសៀមធ្វើមិនបានល្អដូចខ្មែរយើងឡើយ ។

ជំនឿព្រហ្មញ្ញសាសនា ពិសេសពិធីក្នុងព្រះរាជវាំង និង ពិធីបុណ្យទ្វារទសមាស ដូចជាព្រះរាជពិធីច្រត់ព្រះនង្គ័លព្រះរាជពិធីបុណ្យអុំទូក ព្រះរាជពិធីបុណ្យបង្ហោះខ្លែង ។ល។ សៀមធ្វើតាមខ្មែរទាំងអស់ ។ លោក ភីតធើ ចនសិន Peter Johnson សរសេរក្នុងសារពត៌មាន Hindustan Times ចេញផ្សាយថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៨

បានស្រង់សំដីលោក ស៊ូឡាក់សិវៈរក្សា ប្រវត្តិវិទូល្បីល្បាញរបស់សៀមស្តីពីចក្រភពខ្មែរថា "ការរាតត្បាតរបស់សៀមលើទឹកដីខ្មែរធ្វើឱ្យខ្មែរចុះទន់ខ្សោយ តែសៀមទទួលយកប្រពៃណីទំនៀមទម្លាប់វប្បធម៌ខ្មែរ រួមទាំងជំនឿលើលទ្ធិទេវរាជ និង របៀបរៀបចំពិធីនៅក្នុងវាំង ហើយជំនឿជាទីពេញចិត្តកំពុងពេញនិយមសព្វថ្ងៃ ពិសេសក្នុងជួរអ្នកនយោបាយសៀម គឺយ័ន្តមន្តអាគមគាថា" ។

សេចក្តីសង្ខេបប្រវត្តិសាស្ត្រ ដែលបានរៀបរាប់ខាងលើបង្ហាញឱ្យឃើញថា សុខោទ័យ ជាកំណើតរបស់រដ្ឋសៀមបានបង្កើតឡើង នាសតវត្សរ៍ទី ១៣ គឺមានអាយុប្អូនប្រាសាទព្រះវិហារច្រើនសតវត្សរ៍ ។

ប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា សៀមជាពួកនៅយូណានខ្ចាត់ព្រាត់ចុះមករាតត្បាតដណ្តើមទឹកដីខ្មែរ ហើយយកវប្បធម៌ខ្មែរជាកត្តាផ្តល់ចំណេះឱ្យពួកគេកសាងរដ្ឋថ្មីមួយរីកចម្រើនជាប្រទេសថៃឡង់ដ៏សព្វថ្ងៃ ។ បច្ចុប្បន្ននេះនាសតវត្សរ៍ទី ២១ទៅហើយ សៀមនៅតែបង្កើតព្រឹត្តិការណ៍បែបអនារ្យជនតាមព្រំដែនបង្ហាញឱ្យខ្មែរយើងឃើញជាក់នឹងភ្នែក គឺសកម្មភាពបន្តរាតត្បាតយកទឹកដី និងសម្បត្តិវប្បធម៌ខ្មែរ ទំនងជាសៀមមិនទាន់បញ្ចប់នៅឡើយទេ ។ ស្របដូចលោក អនុម៉ាន បានសរសេរលើទំព័រទី ១០ ក្នុងសៀវភៅរបស់លោក Essay on Thai Folklore ថា The Thai never ceased to be on the move សៀមមិនដែលបានឈប់ធ្វើចលនាទៅមុខសោះ។

ដូច្នេះ ខ្មែរត្រូវតែជឿលើខ្លួនឯង ពង្រឹងខ្លួនឯងឱ្យរឹងមាំ ដោយផ្អែកលើវប្បធម៌ខ្មែរ គួបផ្សំជាមួយបច្ចេកវិទ្យាទំនើប ខ្មែរមានប្រាជ្ញា បារមី ថាមពលខ្លាំងក្លា ការពារបានវប្បធម៌ជាតិនិងទឹកដី និងអាចអភិវឌ្ឍន៍ប្រទេសរីកចម្រើនឆាប់រហ័ស។ ខ្មែរត្រូវតែយល់ឱ្យច្បាស់ថា សត្វសារិកាចូលចិត្តស៊ីផ្លែម្ទេស ទោះបីចេះនិយាយគ្រាប់តាមភាសាខ្មែរបានពីរោះគួរជាទីស្រឡាញ់យ៉ាងណាក៏ដោយ ក៏សត្វស្លាបនេះពុំអាចក្លាយជាមនុស្សខ្មែរកើតឡើយ ។

មនុស្សខ្មែរត្រូវតែប្រុងប្រយ័ត្នជានិច្ច និងជឿលើពាក្យប្រៀនប្រដៅរបស់ដូនតាយើងថា "ឈើកោងវល្លិព័ទ្ធ មនុស្សខ្ចាត់ព្រាត់ កុំយកខ្លួនបៀត" ។

ប្រភពពត៌មានៈ សារពត៌មានរស្មីកម្ពុជា

ថ្ងៃអង្គារ ៤កើត ខែបុស្ស ឆ្នាំជូត សំរឹទ្ធិស័ក ព.ស.២៥៥២ ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ គ.ស.២០០៨